**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងទេសចរណ៍**

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពីការរៀបចំពិធីបើកជាផ្លូវការ
## "ឆ្នាំនៃការផ្លាស់ប្តូរប្រជាជននិងប្រជាជន កម្ពុជា-ចិន ២០២៤"

ខេត្តសៀមរាប ថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៤ – ក្រសួងទេសចរណ៍ សហការជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋបាលខេត្តសៀមរាប និងក្រសួង ស្ថាប័នពាក់ព័ន្ធ បានរៀបចំពិធីប្រកាសបើកជាផ្លូវការ **"ឆ្នាំនៃការផ្លាស់ប្តូរប្រជាជននិងប្រជាជន កម្ពុជា-ចិន ២០២៤"** ដែលបានប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចពិជ័យសេនា ទៀ បាញ់** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និង **ឯកឧត្តម លី ស៊ូឡឺ** សមាជិកការិយាល័យនយោបាយ និងជារដ្ឋមន្ត្រីក្រសួងឃោសនាការនៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តចិន និងមានការចូលរួមពីថ្នាក់ដឹកនាំជាសមាជិករដ្ឋសភា ថ្នាក់ដឹកនាំតំណាងក្រសួង ស្ថាប័ន គណៈអភិបាលរាជធានី ខេត្ត ដៃគូឯកជន វិនិយោគិន អ្នកសារព័ត៌មាន ក្រុមសិល្បករ-សិល្បការិនីតារាល្បីៗ រួមជាមួយភ្ញៀវទេសចរចម្រុះកម្ពុជា-ចិន ប្រមាណជាង ១,០០០នាក់។ ពិធីដ៏មានអត្ថន័យជ្រាលជ្រៅនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងបង្កើនទំនាក់ទំនងក្នុងវិស័យទេសចរណ៍ និងវប្បធម៌រវាងប្រទេសទាំងពីរ និងជំរុញការផ្លាស់ប្តូររវាងប្រជាជននិងប្រជាជន ជាពិសេសការផ្លាស់ប្តូរក្នុងចំណោមយុវជន និងថ្នាក់ដឹកនាំជំនាន់ក្រោយនៃប្រទេសទាំងពីរ ដើម្បីរួមចំណែកដល់ការសម្រេចបំណងប្រាថ្នាក្នុងការកសាងសហគមន៍ជោគវាសនារួមគ្នារវាងកម្ពុជា-ចិន។

នាឱកាសពិធីប្រកាសបើកជាផ្លូវការនេះ **ឯកឧត្តម សុខ សូកេន រដ្ឋមន្ត្រីក្រសួងទេសចរណ៍** បានថ្លែងសុន្ទរកថាស្វាគមន៍ និងបានអានសារលិខិតអបអរសាទររបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដោយបានគូសបញ្ជាក់ថា ព្រឹត្តិការណ៍ **"ឆ្នាំនៃការផ្លាស់ប្តូរប្រជាជននិងប្រជាជន កម្ពុជា-ចិន ២០២៤"** ជាគំនិតផ្តួចផ្តើមរបស់ថ្នាក់ដឹកនាំប្រទេសទាំងពីរក្នុងការជំរុញការផ្លាស់ប្តូរប្រជាជននិងប្រជាជន កម្ពុជា-ចិន ដើម្បីពង្រឹងចំណងមិត្តភាព **"កិច្ចសហប្រតិបត្តិការឥតងាករេ"** រវាងកម្ពុជា-ចិន ដែលបានបង្ហាញនូវការប្តេជ្ញាចិត្តក្នុងការពង្រឹង និងពង្រីកទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរឱ្យកាន់តែស៊ីជម្រៅ និងការដាក់ចេញនូវគំនិតផ្តួចផ្តើម **"ខ្សែក្រវាត់ និងផ្លូវ"** ឆ្ពោះទៅរកការកសាងសហគមន៍ជោគវាសនារួមក្នុងយុគ្គសម័យថ្មីរវាងប្រទេសទាំងពីរ។

**ឯកឧត្តម ស៊ុន យេលី រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងទេសចរណ៍នៃសាធារណរដ្ឋប្រជាមានិតចិន** បានអានសារលិខិតអបអរសាទររបស់ **ឯកឧត្តម លី ឈាំង នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតចិន** ដែលមានសុទិដ្ឋិនិយមថា ប្រទេសទាំងពីរនឹងចាប់យក **"ឆ្នាំនៃការផ្លាស់ប្តូរប្រជាជននិងប្រជាជន កម្ពុជា-ចិន ២០២៤"** ជាឱកាសដើម្បីរៀបចំសកម្មភាពផ្លាស់ប្តូរប្រជាជននិងប្រជាជនឱ្យកាន់តែច្រើន រួមគ្នាអនុវត្តគំនិតផ្តួចផ្តើមអរិយធម៌សកលលោក ជំរុញកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរឱ្យកាន់តែស៊ីជម្រៅលើគ្រប់វិស័យ។

ក្នុងនាមជាប្រធានគណៈប្រតិភូភាគីចិន **ឯកឧត្តម លី ស៊ូឡឹ សមាជិកការិយាល័យនយោបាយ និងជារដ្ឋមន្ត្រីក្រសួងឃោសនាការនៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តចិន** បានថ្លែងសុន្ទរកថា ដោយបានសង្កត់ធ្ងន់ថា ចិន និងកម្ពុជា គឺជាអ្នកជិតខាងល្អ និងជាមិត្តពិតប្រាកដដែលចេះជួយគ្នាទៅវិញទៅមក។ ប្រទេសទាំងពីរមានប្រវត្តិសាស្ត្រយូរអង្វែងក្នុងការផ្លាស់ប្តូររវាងប្រជាជន និងប្រជាជន **“យើងគួរតែរួមគ្នាលើកកម្ពស់ការផ្លាស់ប្តូរ និងការរៀនសូត្រពីអរិយធម៌គ្នាទៅវិញទៅមក”** ពិសេស រួមគ្នាពង្រីកការផ្លាស់ប្តូរវិស័យទេសចរណ៍ ដែលជាមធ្យោបាយដ៏សំខាន់ក្នុងការផ្លាស់ប្តូររវាងប្រជាជន និងប្រជាជន។

សម្រាប់ភាគីកម្ពុជា **សម្តេចពិជ័យសេនា ទៀ បាញ់ ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ** បានលើកឡើងថា កម្ពុជាពិតជាមានសុទិដ្ឋិនិយម និងគាំទ្រយ៉ាងពេញទំហឹងនូវការដាក់ចេញនូវគំនិតផ្តួចផ្តើម **“ខ្សែក្រវាត់ និងផ្លូវ”** របស់ **ឯកឧត្តមប្រធានាធិបតី ស៊ី ជីនពីង** នៅឆ្នាំ២០១៣ ដែលកម្ពុជាបានចូលរួមជាសមាជិកស្ថាបនិកមួយ។ កម្ពុជាជឿជាក់ថា **“គំនិតផ្តួចផ្តើមខ្សែក្រវាត់ និងផ្លូវ”** ពិសេសការកំណត់ឆ្នាំ២០២៤ ជា **“ឆ្នាំនៃការផ្លាស់ប្តូរប្រជាជននិងប្រជាជន កម្ពុជា-ចិន”** នឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមចំណែកពង្រឹងសាមគ្គីភាព និងលើកកម្ពស់កិច្ចសហប្រតិបត្តិការដ៏ជិតស្និទ្ធរវាងបណ្តាប្រទេសទាំងក្នុងតំបន់ និងពិភពលោក លើវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម ការវិនិយោគ ហេដ្ឋារចនាសម្ព័ន្ធ ការផ្លាស់ប្តូរវប្បធម៌ និងទំនាក់ទំនងរវាងប្រជាជននិងប្រជាជន។

ព្រឹត្តិការណ៍នេះ បានប្រព្រឹត្តទៅប្រកបដោយជោគជ័យគ្រប់គ្រាន់ ដោយមានការបញ្ចាំងវីដេអូមិត្តភាពកម្ពុជា-ចិន ការវាយស្គរប្រកាសបើកជាផ្លូវការ **“ឆ្នាំនៃការផ្លាស់ប្តូរប្រជាជននិងប្រជាជន កម្ពុជា-ចិន ២០២៤”** ដោយថ្នាក់ដឹកនាំនៃប្រទេសទាំងពីរ អមដោយការសម្តែងទស្សនីយភាពសិល្បៈរួមគ្នាដោយសិល្បករ-សិល្បការិនីជាតិរបស់កម្ពុជា និងសិល្បករ-សិល្បការិនីល្បីៗថ្នាក់មជ្ឈិម បានអញ្ជើញមកពីប្រទេសចិនដើម្បីចូលរួមទស្សនា និងសម្តែងដោយផ្ទាល់ ដែលការសម្តែងទស្សនីយភាពសិល្បៈដល់កម្រិតមជ្ឈិមបែបនេះ សម្រាប់តែថ្នាក់ដឹកនាំកំពូលរបស់ប្រទេសប៉ុណ្ណោះ។ នេះសបញ្ជាក់ឱ្យឃើញថា ប្រមុខដឹកនាំប្រទេសទាំងពីរយកចិត្តទុកដាក់ខ្ពស់សម្រាប់កម្មវិធីដ៏មានសារៈសំខាន់នេះ។

ជាមួយការរៀបចំពិធីបើក **“ឆ្នាំនៃការផ្លាស់ប្តូរប្រជាជននិងប្រជាជន កម្ពុជា-ចិន ឆ្នាំ២០២៤” ឯកឧត្តមរដ្ឋមន្ត្រីក្រសួងទេសចរណ៍** បានជួបពិភាក្សាជាមួយប្រតិភូក្រុមហ៊ុនចិនជាច្រើនរូប ដែលដឹកនាំដោយ **លោក** Xu Zhengzhong **ប្រធានក្រុមហ៊ុន** Bauhinia Culture Group Corporation Limited ដោយផ្តោតសំខាន់លើការរើរកផ្លូវសម្រាប់កិច្ចសហប្រតិបត្តិការទេសចរណ៍វប្បធម៌ ដើម្បីត្រួសត្រាយផ្លូវសម្រាប់ការបង្កើនការវិនិយោគ និងការយល់ដឹងកាន់តែស៊ីជម្រៅ។

**ឯកឧត្តមរដ្ឋមន្ត្រី** ក៏បានជួបពិភាក្សាការងារជាមួយ **លោក** Liu Minglin នាយកប្រតិបត្តិនៃក្រុមហ៊ុន Yunnan Provincial Investment Holdings Group Co., Ltd ដើម្បីពង្រឹងចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការ។ ក្រោយជំនួបពិភាក្សាការងារជាមួយប្រតិភូក្រុមហ៊ុនជាច្រើន ក្រសួងទេសចរណ៍បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា (MoU) ស្តីពីការរួមគ្នាបង្កើនការអភិវឌ្ឍវិស័យទេសចរណ៍ រួមទាំងវប្បធម៌នៅខេត្តសៀមរាប រវាងក្រសួងទេសចរណ៍ជាមួយក្រុមហ៊ុន Yunnan Provincial Investment Holdings Group Co., Ltd ផងដែរ នាថ្ងៃទី១៤ ខែមករា ឆ្នាំ២០២៤។